**សន្ទរកថាបើក ដោយ អ៊ីវ៉ាន ស៊ីម៉ូនូវិច (Ivan Šimonović) ឧបការីអគ្គលេខាធិការ ទទួលបន្ទុកសិទ្ធិមនុស្ស នៅក្នុងសន្និសីទស្តីពីសិទ្ធិមនុស្ស និងបទដ្ឋានបោះឆ្នោត ប្រារព្ធធ្វើនៅមជ្ឈមណ្ឌលខាតធី (Carter Center) ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៥ អាត់ឡង់តា សហរដ្ឋអាមេរិក**

លោក លោកស្រីជាទីរាប់អាន!

ខ្ញុំមានកិត្តិយសដែលបានមកធ្វើជាសហប្រធានសន្និសីទស្តីពីសិទ្ធិមនុស្ស និងបទដ្ឋានបោះឆ្នោតនេះ រួមជាមួយនឹងលោកប្រធានមជ្ឈមណ្ឌលខាតធី។ ខ្ញុំសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលខាតធីដែលបានរៀបចំសន្និសីទយ៉ាងទាន់ពេលវេលានេះឡើង។

ខ្ញុំសូមចាប់ផ្តើមដកស្រង់នូវសំដីរបស់អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណាន់ ដែលមានប្រសាសន៍ថា "ការកសាងលទ្ធិប្រជាធិបតេយ្យគឺជាដំណើរការស្មុគស្មាញមួយ។ ការបោះឆ្នោតគ្រាន់តែជាចំណុចចាប់ផ្តើមប៉ុណ្ណោះ ប៉ុន្តែប្រសិនបើ គេព្រមពៀងទទួលយកសុច្ចរិតភាពនៃការឆ្នោតនោះ វាគឺជាធម្មានុរូបនៃប្រជាធិបតេយ្យហើយ។"

ដូចដែលបានទទួលស្គាល់ដោយសេចក្តីប្រកាសស្តីពីគោលការណ៍នៃការអង្កេតការណ៍លើការបោះឆ្នោតអន្តរជាតិ ថា "ការបោះឆ្នោតបែបប្រជាធិបតេយ្យពិតប្រាកដគឺជាបុរេលក្ខខណ្ឌសម្រាប់អភិបាលកិច្ចប្រជាធិបតេយ្យ។" តាមពិត លទ្ធភាពរបស់ប្រជាពលរដ្ឋគ្រប់រូបអាចជ្រើសរើសតំណាងរបស់ខ្លួន គឺជាប្រការសំខាន់សម្រាប់លទ្ធិប្រជាធិបតេយ្យ។ វាក៏ជាសិទ្ធិមនុស្សមួយដែរ ដែលមានចែងទាំងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ទាំងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

ជារឿយៗ ការរំលោភសិទ្ធិមនុស្ស កើតមាននៅអំឡុងពេលមុនការបោះឆ្នោត គឺ ជាសូចនាករមួយដែលអាចឲ្យគេដឹងពីអស្ថិរភាពនាពេលខាងមុខ ជាពិសេស ក្នុងអំឡុងពេលក្រោយការបោះឆ្នោត។ ខ្ញុំក៏សូមរំលឹកអ្នកទាំងអស់គ្នាអំពីការបោះឆ្នោតកាលពីឆ្នាំ២០១០ ក្នុងប្រទេសកូតឌីវ័រ។ បរិយាកាសមុនពេលបោះឆ្នោត បានមានការរិតត្បិតជាច្រើនលើសេរីភាពជាមូលដ្ឋានស្រេចទៅហើយ។ ទោះបីជាលទ្ធផលបោះឆ្នោតត្រូវបានទទួលស្គាល់ជាអន្តរជាតិដែលបានប្រកាសថា អ៊ូអាតារ៉ា (Ouattara) ជាអ្នកឈ្នះក៏ដោយ អតីតប្រធានាធិបតី ជីបាកបូ (Gbagbo) បដិសេធមិនព្រមចុះចេញពីតំណែង ។ ព្រឹត្តិការណ៍បន្ទាប់ពីនោះ បានធ្វើឲ្យមនុស្សយ៉ាងហោចណាស់ ៣០០០ នាក់ ស្លាប់ ព្រមទាំងស្ត្រី និងកុមារី ជាង ១៥០នាក់ ត្រូវគេរំលោភសេពសន្ថវៈ ក្នុងអំឡុងរយៈពេលប្រាំមួយខែនៃការកើតមានអំពើហិង្សានយោបាយ និងជម្លោះប្រដាប់អាវុធ។ អំឡុងពេលមានអំពើហិង្សានេះ ក្រោយមកបានក្លាយទៅជា

ប្រធានបទរបស់គណៈកម្មការស៊ើបអង្កេតរបស់ អ.ស.ប និងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ព្រមទាំងក្លាយជាដំណើរការបណ្តឹងព្រហ្មទណ្ឌដោយតុលាការក្នុងស្រុកផងដែរ។

ទោះជាយ៉ាងណាក៏ដោយ ការមិនគោរពដោយផ្ទាល់នូវលទ្ធផលបោះឆ្នោត គឺខុសគ្នាឆ្ងាយពីអ្វីដែលជាបញ្ហាប្រឈមតែមួយគត់ចំពោះការបោះឆ្នោតពិតប្រាកដ។ យើងកំពុងរស់នៅក្នុងយុគសម័យមួយដែលមានមនុស្សកាន់តែច្រើនឡើងៗទទួលស្គាល់ថា ប្រអប់ឆ្នោតតែឯងមិនអាចបង្កើតលទ្ធិប្រជាធិបតេយ្យដោយស្វ័យប្រវត្តបានឡើយ។ យើងបាន និងកំពុងមើលឃើញឧទាហរណ៍រាប់មិនអស់ពីបញ្ហានេះ ទាំងក្នុងពេលកន្លងមក និងទាំងក្នុងពេលបច្ចុប្បន្ននេះ។

ជាច្រើនឆ្នាំកន្លងមកនេះ រដ្ឋសមាជិករបស់ អ.ស.ប បានបញ្ជាក់អះអាងថា លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ ព្រមទាំងសិទ្ធិមនុស្សគឺពឹងអាស្រ័យគ្នា និងពង្រឹងគ្នាទៅវិញទៅមក។ ប្រសិនបើមានផ្នែកណាមួយចុះខ្សោយវាធ្វើឲ្យអន្តរាយភ្លាមៗដល់អស្ថិភាពនៃផ្នែកផ្សេងទៀត។

ប៉ុន្តែ ប្រសិនជា ដូចករណីនៅសាធារណរដ្ឋប៊ូរុនឌី សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ (DRC) ឬប្រទេសអេហ្ស៊ីប មានការបង្ក្រាបដ៏ឃោឃៅលើការតវ៉ាដោយសន្តិវិធី និងមានការចាប់ខ្លួនគូបដិបក្ខ ឬប្រសិនជា ទីភ្នាក់សារព័ត៌មាន ឬកាសែតត្រូវបានត្រួតពិនិត្យ និងដាក់កម្រិតលើការបោះពុម្ពផ្សាយ ហើយការចូលទៅកាន់បណ្តាញព័ត៌មានតាមអនឡាញត្រូវបានរាំងខ្ទប់ ឬប្រសិនជា ដូចករណីនៅប្រទេសភូមា ការរើសអើងស្តែងឲ្យឃើញយ៉ាងច្បាស់ ហើយប្រជាពលរដ្ឋក្នុងតំបន់មួយចំនួនមិនអាចបោះឆ្នោតបានដោយសេរីនោះ អញ្ចឹងទេចរិតលក្ខណៈចាំបាច់នៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌ អាចនឹងចោទជាបញ្ហា បើទោះជាមិនមានភាពមិនប្រក្រតីផ្នែកបច្ចេកទេស ឬការបន្លំសន្លឹកឆ្នោត ត្រូវបានគេរាយការណ៍ក្តី។

ទោះជាយ៉ាងណាក៏ដោយ ជារឿយៗ យើងទំនងជាផ្តោតការយកចិត្តទុកដាក់តែលើដំណើរការបោះឆ្នោតខ្លួនវាផ្ទាល់ ដោយមិនបានយកចិត្តទុកដាក់គ្រប់គ្រាន់លើស្ថានភាពសិទ្ធិមនុស្សនៅពេលរៀបចំធ្វើការបោះឆ្នោតនោះ។ ត្រង់នេះហើយដែលការងារសិទ្ធិមនុស្សអាចដើរតួនាទីមួយយ៉ាងសំខាន់ក្នុងបរិបទនៃការបោះឆ្នោត ។

ម្យ៉ាងវិញទៀត ការដកស្រង់ខ្លឹមសារពីសេចក្តីប្រកាសស្តីពីគោលការណ៍នៃការអង្កេតការណ៍ការបោះឆ្នោតអន្តរជាតិថា៖ "ការបោះឆ្នោតប្រកបដោយប្រជាធិបតេយ្យពិតប្រាកដ មិនអាចនឹងសម្រេចបាននោះទេ លុះត្រាណាតែសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានជាច្រើនផ្សេងទៀត អាចត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន

ដោយមិនមានការរើសអើង។" លទ្ធិប្រជាធិបតេយ្យពិតប្រាកដរីកចម្រើនទៅបាន លុះត្រាតែមានការគោរពសិទ្ធិមនុស្សទាំងអស់ជាមូលដ្ឋាន។

លោក លោកស្រី ជាទីគោរពរាប់អាន!

ខ្ញុំមានក្តីសោមនស្សរីករាយក្រៃលែងដែលសន្និបាតនេះ បានដាក់សិទ្ធិមនុស្សជាចំណុចស្នូលដោយយកបទដ្ឋានបោះឆ្នោតមកធ្វើជាប្រធានបទ។ ដោយសារ យើងនឹងពិនិត្យអំពីទំនាក់ទំនងរវាងការបោះឆ្នោត និងសិទ្ធិមនុស្សក្នុងអំឡុងពីរថ្ងៃនេះ ខ្ញុំសូមឲ្យយើងទាំងអស់គ្នាគិតគូរដល់កាតព្វកិច្ចសិទ្ធិមនុស្សរបស់រដ្ឋ នៅក្នុងអំឡុងពេលនៃដំណើរការបោះឆ្នោត និងអំពីរបៀបដែលភាគីពាក់ព័ន្ធទាំងអស់អាចលើកមកនិយាយ និងប្រើប្រាស់កាតព្វកិច្ចទាំងនេះ ដើម្បីពង្រឹងដំណើរការបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យ។

ការខ្ចីពាក្យមួយមាត់ ដែលគេប្រើប្រាស់ជាទូទៅនៅក្នុងវិស័យកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និងដូចដែលបានគូសបញ្ជាក់នៅក្នុងរបៀបវារៈនៃកិច្ចប្រជុំនេះ យើងគួរពិភាក្សាគ្នាអំពីវិធីសាស្ត្រនៃការបោះឆ្នោតផ្តោតលើសិទ្ធិមនុស្សជាសំខាន់។

វិធីសាស្ត្រនៃការបោះឆ្នោតផ្តោតលើសិទ្ធិមនុស្សជាសំខាន់ មានន័យថា គោលការណ៍សិទ្ធិមនុស្ស (បានកើតចេញពីកាតព្វកិច្ចច្បាប់សិទ្ធិមនុស្ស) គួរតែប្រើប្រាស់ធ្វើជាមគ្គុទ្ទេសន៍សម្រាប់ការងារបោះឆ្នោត ដែលគេហៅថា៖ សកលភាព អវិភាគីយភាព ភាពពឹងអាស្រ័យគ្នាទៅវិញទៅមក សមភាព និងការមិនរើសអើង ការចូលរួម និងការរាប់បញ្ចូល គណនីយភាព និងនីតិរដ្ឋ។

វានិយាយសំដៅដល់ផងដែរថា បុគ្គលទាំងអស់ដែលចូលរួមក្នុងការងារពាក់ព័ន្ធនឹងការបោះឆ្នោត មានដូចជា៖ អង្គភាព អ.ស.ប អង្គការអន្តររដ្ឋាភិបាល អង្គការក្នុងតំបន់ អង្គការសង្គមស៊ីវិល អ្នកអង្កេតការណ៍ និងបុគ្គលផ្សេងទៀត ស្គាល់ច្បាស់ពីបទដ្ឋាន និងគោលការណ៍សិទ្ធិមនុស្ស និងអំពីរបៀបដែលបទដ្ឋាន និងគោលការណ៍សិទ្ធិមនុស្សទាំងនេះ ត្រូវបានអនុវត្តជាក់ស្តែងនៅក្នុងសកម្មភាព ការងាររាល់ថ្ងៃរបស់ខ្លួននៅក្នុងបរិបទនៃការបោះឆ្នោត។

ពិសេសជាងនេះទៅទៀត ការអនុវត្តវិធីសាស្ត្រផ្តោតលើសិទ្ធិមនុស្សជាសំខាន់ នៅគ្រប់ដំណាក់កាលទាំងអស់នៃការងារបោះឆ្នោតដែលពាក់ព័ន្ធនឹង៖

- ការរួមបញ្ចូលសិទ្ធិទាំងអស់ មានដូចជា សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅក្នុងការវិភាគណាមួយអំពី បរិបទនៃការបោះឆ្នោត

o ការផ្តោតការយកចិត្តទុកដាក់លើការមិនរើសអើង និងសមភាព ព្រមទាំងការធានាឲ្យមានការចូលរួមយ៉ាងសកម្ម និងប្រកបដោយអត្ថន័យពីសំណាក់បុគ្គលគ្រប់រូប ជាពិសេស ជនដែលបាត់បង់ឱកាសបំផុត ស្ត្រី សមាជិកជនភាគតិច និងជនជាតិដើមភាគតិច និង
o ការពង្រឹងសមត្ថភាពរបស់រដ្ឋនានា ក្នុងការគោរព ការការពារ និងការបំពេញកាតព្វកិច្ចសិទ្ធិមនុស្ស ព្រមទាំងការពង្រឹងសមត្ថភាពរបស់បុគ្គលក្នុងការទាមទារសិទ្ធិរបស់ខ្លួន ។

លោក លោកស្រី ជាទីគោរពរាប់អាន!

ខ្ញុំសូមធ្វើការសន្និដ្ឋាន។ ផ្អែកតាមមេរៀនទទួលបានពីថ្នាក់តំបន់ នៅក្នុងវិស័យអភិវឌ្ឍ បានបង្ហាញពីរបៀបដែលវិធីសាស្ត្រផ្តោតលើសិទ្ធិមនុស្សជាសំខាន់ ផ្តល់លទ្ធផល ប្រកបដោយសមធម៌ និងចិរភាពកាន់តែច្រើនឡើង ដោយសារតែវិធីសាស្ត្រនេះផ្តល់សិទ្ធិអំណាចដល់អ្នកដែលទាមទារសិទ្ធិរបស់ខ្លួន រួមចំណែកកាត់បន្ថយការរើសអើង និងដោះស្រាយអសមភាព គៀរគរអ្នកបោះឆ្នោតគាំទ្រ ព្រមទាំងកសាងគណនីយភាព ។

ពីរថ្ងៃទៀត យើងនឹងរំលឹកឡើងវិញពីកាតព្វកិច្ចសិទ្ធិមនុស្សដែលត្រូវអនុវត្តលើការងារបោះឆ្នោត និងការងារពាក់ព័ន្ធរបស់យន្តការសកល និងតំបន់។ យើងនឹងពិភាក្សាគ្នាផងដែរ អំពីរបៀបដែលអ្នកអង្កេតការណ៍អាចប្រើប្រាស់បទដ្ឋានទាំងនេះ និងអំពីការងារសម្របសម្រួល។ ហើយថាតើ ហេតុអ្វីបានជាមិនអាចទៅរួច បើរបៀបដែលវិធីសាស្ត្រផ្តោតលើសិទ្ធិមនុស្សជាសំខាន់នេះ អាចរួមវិភាគទានជាវិជ្ជមានដល់ការបោះឆ្នោតប្រកបដោយប្រជាធិបតេយ្យ និងអាចជឿទុកចិត្តនោះ?

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) និងយន្តការសិទ្ធមនុស្សដែលខ្លួនគាំទ្របាន និងកំពុងបង្កើតបទពិសោធន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងការបកស្រាយ និងអនុវត្តនិយាម និងបទដ្ឋានសិទ្ធិមនុស្ស រួមទាំងបរិបទនៃការបោះឆ្នោតផងដែរ។ ចូរយើងពិភាក្សាអំពីរបៀបដែល តួរអង្គផ្សេងៗដែលបានចូលរួមក្នុងការងារបោះឆ្នោតអាចធ្វើការជាមួយគ្នាដើម្បីជៀសវាងការងារត្រួតស៊ីគ្នារ និងអំពីថាតើការងារអ្វីខ្លះ ដែលតួអង្គទាំងនោះ អាចធ្វើដើម្បីជាការជួយបំពេញបន្ថែមគុណតម្លៃបាន ។

ជាទីបញ្ចប់ ខ្ញុំសូមអនុញ្ញាតសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅជាថ្មីម្តងទៀតដល់វាគ្មិន និងសិក្ខាកាមទាំងអស់ និងសូមថ្លែងអំណរគុណជាថ្មីម្តងទៀតផងដែរ ដល់មជ្ឈមណ្ឌលខាតធី ចំពោះការរៀបចំឲ្យមានសន្និសីទនេះឡើង។ ខ្ញុំទន្ទឹងរង់ចាំដោយក្តីសោមនស្សរីករាយនូវការតស៊ូមតិប្រកបដោយថាមវន្ត និងផ្លែផ្កា។

សូមអរគុណ។